សន្និបាតលើកទី១៣៦របស់សហភាពអន្តរសភា (IPU)
ទីក្រុង ដាកា ប្រទេសបង់ក្លាដែស ថ្ងៃទី១-៥ មេសា ២០១៧

Inter-Parliamentary Union
For democracy. For everyone.

# សំណៅមិនអាចកែបាន

ក្រុមប្រឹក្សាភិបាល
ចំណុចរបៀបវារៈទី ១១(ខ)

CL/200/11(b)-R.3
ទីក្រុងដាកា ៥មេសា ២០១៧

# សេចក្តីសម្រេចរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់សភា

## មាតិកា

Page

## Americas


- **Venezuela**

VEN10 Biagio Pilieri
VEN11 José Sánchez Montiel
VEN12 Hernán Alemán
VEN13 Richard Blanco

VEN14 Richard Mardo
VEN15 Gustavo Marcano
VEN16 Julio Borges
VEN17 Juan Carlos Caldera
VEN18 María Corina Machado (Ms.)
VEN19 Nora Bracho (Ms.)
VEN20 Ismael García
VEN21 Eduardo Gómez Sigala
VEN22 William Davila
VEN23 María Mercedes Aranguren (Ms.)

VEN24 Nirma Guarulla (Ms.)
VEN25 Julio Ygarza
VEN26 Miguel Tadeo

VEN27 Rosmit Mantilla
VEN28 Enzo Prieto
VEN29 Gilberto Sojo

VEN30 Gilber Caro

VEN31 Luis Florido
VEN32 Eudoro Gonzalez
*Draft decision* ........................................................................................ *1*


E

#IPU136

CL/200/11(b)-R.3 - ii -
Dhaka, 5 April 2017

## កម្ពុជា

CMBD/២៧ - ចាន់ ចេង
CMBD/៤៨ - (អ្នកស្រី) មូរ សុខហួរ
CMBD/៤៩ - កែវ ភីរម្យ
CMBD/៥០ - ហូ វ៉ាន់
CMBD/៥១ - ឡុង រី
CMBD/៥២ - នុត រំដួល
CMBD/៥៣ - ម៉ែន សុថាវរិន
CMBD/៥៤ - រៀល ខេមរិន្ទ
CMBD/៥៥ - ហុង សុខហួរ
CMBD/៥៦ - គង់ សភា
CMBD/៥៧ - ញ៉យ ចំរើន

CMBD/៥៨ - សម រង្ស៊ី
CMBD/៥៩ - អ៊ុំ សំអាន
CMBD/៦០- គឹម សុខា
CMBD/៦១ - (អ្នកស្រី) ថាក់ ឡានី

*ពង្រាងសេចក្តីសម្រេច* ..........13

គណៈកម្មាធិការ

*សម្រេច* ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលនៃសហភាពអន្តរសភា សូមឲ្យអនុម័តលើសេចក្តីសម្រេចដូចខាងក្រោមនេះ ៖

ក្រុមប្រឹក្សាភិបាលនៃសហភាពអន្តរសភា (IPU)

*យោង*សំណុំរឿងរបស់តំណាងរាស្ត្រចំនួន១៥ រូប ដូចមានរាយឈ្មោះខាងក្រោម មកពីគណៈបក្សសង្គ្រោះជាតិ (CNRP) ដែលសុទ្ធតែជាសមាជិកសំខាន់ៗនិងដែលបានបំរើការយូរនៃថ្នាក់ដឹកនាំគណៈបក្សសង្គ្រោះជាតិ(CNRP) រួមមាន ៖ លោក ចាន់ ចេង អ្នកស្រី មូរ សុខហួរ លោក កែវ ភីរម្យ លោក ហូ វ៉ាន់ លោក ឡុង រី លោក នុត រំដួល លោក ម៉ែន សុថាវរិន និងលោក រៀល ខេមរិន្ទ លោក ហុង សុខហួរ លោក គង់ សភា លោក ញ៉យ ចំរើន លោក សម រង្ស៊ី លោក អ៊ុំ សំអាន លោក គឹម សុខា អ្នកស្រី ថាក់ ឡានី និងសេចក្តីសម្រេចបានអនុម័តនាសម័យប្រជុំលើកទី១៩៩ របស់ខ្លួន (នៅទីក្រុងហ្សឺណែវ តុលា ឆ្នាំ២០១៦)។

*យោង*សវនាកាដែលបានធ្វើឡើងជាមួយគណៈប្រតិភូកម្ពុជានាសម័យប្រជុំលើកទី១៣៦ នៃសហភាពអន្តរសភា (IPU) ព្រមទាំងមានការចូលរួមពីលោកស្រី សួម៉ូរ៉ា ជូឡុង ក្នុងនាមគណៈបក្សសង្គ្រោះជាតិ (CNRP)

*យោង*របាយការណ៍ចុងក្រោយ(CL/199/11(b)-R.1) ស្តីពីដំណើរទស្សនកិច្ចរបស់គណៈកម្មាធិការនេះ មកកាន់ប្រទេសកម្ពុជា ក្នុងខែកុម្ភៈ ឆ្នាំ២០១៦។

*ដោយរំលឹកឡើងវិញ*អំពីលិខិតចុះថ្ងៃទី១១ ខែកក្កដា និងលិខិតចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ របស់អគ្គលេខាធិការរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងព័ត៌មានដែលបានបញ្ជូនដោយអ្នកប្ដឹង និងតតីយភាគីដែលអាចជឿទុកចិត្តបាន ក៏ដូចជាសវនាការដែលបានធ្វើឡើងជាមួយគណៈប្រតិភូកម្ពុជា និងអ្នកប្ដឹងនាសម័យប្រជុំលើកទី១៣៥ នៃសហភាពអន្តរសភា(IPU) (នាទីក្រុងហ្សឺណែវ ខែតុលា ឆ្នាំ២០១៦)។

*ដោយយល់ឃើញថា* ការទាមទាររបស់អ្នកប្ដឹងដែលករណីទាំងនេះកំពុងស្ថិតក្រោមការត្រួតពិនិត្យ បង្ហាញថាគណបក្សកាន់អំណាចកំពុងព្យាយាមធ្វើឲ្យចុះខ្សោយ បិទមាត់ និងផាត់គណបក្សប្រឆាំងចេញពីការបោះឆ្នោតនាពេលខាងមុខគឺ

ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧និងការបោះឆ្នោតជាតិឆ្នាំ២០១៨ តាមរយៈមធ្យោបាយផ្សេងៗរាប់ទាំង៖ (i) សកម្មភាពបំភិតបំភ័យនិងការគាបសង្កត់ (ii) ការអំពើហិង្សាលើរូបកាយប្រឆាំងនឹងសមាជិកសភា (iii) ការយាយីផ្នែក តុលាការមកលើអ្នកនយោបាយ ដែលបានស្ដែងឲ្យឃើញតាមរយៈការកើនឡើងនៃការចោទប្រកាន់ដោយគ្មានមូលដ្ឋានពីបទព្រហ្មទណ្ឌ និងដំណើរសវនាការ និងការផ្ដន្ទាទោសផ្លូវតុលាការដោយអយុត្តិធម៌ ក៏ដូចជា ការព្យួរបទចោទប្រកាន់ដើម្បី រក្សាទុកការគំរាមអចិន្ត្រៃយ៍នៃការចាប់ខ្លួន (iv) ការផាត់ចេញពីការចូលរួមក្នុងជីវភាពនយោបាយ និងការមិនឲ្យចូលក្នុងប្រទេសកម្ពុជានៃអតីតមេដឹកនាំគណបក្សប្រឆាំង និង (v) ការគំរាមព្យួរ និងការរំលាយគណបក្សសង្គ្រោះជាតិ និងការហាមប្រាមនៅថ្ងៃអនាគតនូវសកម្មភាពនយោបាយរបស់ថ្នាក់ដឹកនាំថ្មីរបស់ខ្លួន អនុលោមតាមវិសោធនកម្មដែលបានអនុម័តកាលពីពេលថ្មីៗនូវច្បាប់ស្ដីពីគណបក្សនយោបាយឆ្នាំ១៩៩៧

*ដោយរំលឹកឡើងវិញ* នូវព័ត៌មានដែលមានរួចហើយនៅក្នុងសំណុំឯកសារទាក់ទងនឹងសំណុំរឿងក្ដីរបស់សមាជិកសភាចំនួន១៥ រូប ដែលករណីរបស់ពួកគាត់ត្រូវបានបញ្ជូនទៅគណៈកម្មាធិការសិទ្ធិមនុស្សរបស់សមាជិកសភាតាំងពីខែកក្កដា ឆ្នាំ ២០១៤ ៖

- **លោក ចាន់ ចេង** ជាសមាជិកមួយរូបនៃរដ្ឋសភា ត្រូវបានតុលាការផ្ដន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥។ អភ័យឯកសិទ្ធិរបស់គាត់ មិនទាន់ត្រូវបានដកហូតដោយនីតិកាលរដ្ឋសភាបច្ចុប្បន្នទេ។ លោកនៅមានសេរីភាព រងចាំសេចក្ដីសម្រេចចុងក្រោយរបស់សាលាឧទ្ធរណ៍។ បណ្ដឹងរបស់គាត់បានរងចាំសវនាការសាលាឧទ្ធរណ៍អស់ពេលពីរឆ្នាំហើយ។ ដំណើរការក្ដីដែលនៅទ្រឹងរយៈពេលដ៏វែងហើយដែលគេជឿជាក់ថាត្រូវបានលើកលែងចោទប្រកាន់នៅឆ្នាំ២០១២ ប៉ុន្តែភ្លាមៗក៏ស្រាប់តែរឿងក្ដីនេះដំណើរការឡើងវិញនៅពាក់កណ្ដាលឆ្នាំ២០១៤ នៅខណៈពេលដែលមានការជាប់គាំងនយោបាយតានតឹង រវាងគណៈបក្សកាន់អំណាច និងគណៈបក្សប្រឆាំង ទាក់ទងនឹងការតវ៉ាលទ្ធផលបោះឆ្នោតឆ្នាំ២០១៣។

- **អ្នកស្រី មូរ សុខហួរ លោក កែវ ភីរម្យ លោក ហូ វ៉ាន់ លោក ឡុង រី លោក នុត រំដួល លោក ម៉ែន សុថាវិរិន លោក រៀល ខេមរិន្ទ** ទាំងអស់គ្នាគឺជាសមាជិកសភា ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ជាមួយនឹងសកម្មជនគណៈបក្សប្រឆាំងផ្សេងទៀត បន្ទាប់ពីមានបាតុកម្មមួយដែលអំពាវនាវឲ្យបើកឡើងវិញនូវទីលានតវ៉ាមួយកន្លែងនៅរាជធានីភ្នំពេញ ដែលគេស្គាល់ថាជាទីលានសេរីភាព (ឬទីលានប្រជាធិបតេយ្យ) បានកើតមានអំពើហិង្សា។ ពួកគេត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ចោទប្រកាន់ពីបទដឹកនាំ កុប្បកម្ម បទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងញុះញង់ឲ្យប្រព្រឹត្តបទល្មើស ហើយដែលត្រូវប្រឈមទោសជាប់ពន្ធនាគាររហូតដល់ទៅ ៣០ ឆ្នាំ។ គណៈកម្មាធិការ បានទទួលភស្តុតាងជាខ្សែវីដេអូយ៉ាងច្បាស់ថា សមាជិកសភាបានព្យាយាមទប់ស្កាត់ និងបញ្ឈប់អំពើហិង្សា (បើទោះជាអ្នកតវ៉ាមិនស្ដាប់ពួកគេក៏ដោយ) ទន្ទឹមនេះ មិនមានភស្តុតាងណាមួយបានបញ្ជូនមក ដើម្បីបញ្ជាក់ការអះអាងពីការចូលរួមរបស់ពួកគេដោយផ្ទាល់ ក្នុងអំពើហិង្សានេះឡើយ ឬថាអំពើហិង្សានេះបំពេញលក្ខខណ្ឌតម្រូវដោយច្បាប់នេះ ពីបទល្មើសកុប្បកម្មនោះក៏ទេដែរ។ សមាជិកសភាទាំងនេះ ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ

បណ្ដោះអាសន្ននៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ បន្ទាប់ពីមានការប្រកាសអំពីកិច្ចព្រមព្រៀងនយោបាយមួយ រវាងរដ្ឋាភិបាល និងគណៈបក្សប្រឆាំង ដើម្បីបញ្ចប់វិបត្តិនយោបាយ។ ទោះជាដូច្នេះក្ដី បទចោទប្រកាន់ប្រឆាំងពួកគេ នៅមិនទាន់ទម្លាក់ចោលនៅឡើយទេ។ ការស៊ើបអង្កេតជាសម្ងាត់របស់តុលាការនៅតែបន្ត ហើយមិនទាន់មានការកំណត់កាលបរិច្ឆេទសម្រាប់ការជំនុំជម្រះនៅឡើយអស់ពេលជិតបីឆ្នាំហើយគិតចាប់ពីមានការតវ៉ានេះមក។

- **លោក ហុង សុខហួរ** ជាសមាជិកព្រឹទ្ធសភា ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ បន្ទាប់ពីមានខ្សែវីដេអូឃ្លីបមួយ ត្រូវបានបង្ហោះនៅលើទំព័រហ្វេសប៊ុករបស់មេដឹកនាំគណៈបក្សប្រឆាំងគឺ លោក សម រង្ស៊ី នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥។ ខ្សែវីដេអូឃ្លីបនេះ បានបង្ហាញរូបភាពរបស់លោក ហុង សុខហួរ កំពុងពិភាក្សាលើទស្សនៈរបស់គាត់ អំពីបញ្ហាព្រំដែនវៀតណាម-កម្ពុជា ដែលជាបញ្ហាមួយដ៏ចម្រូងចម្រាស់ និងរសើបនៅកម្ពុជា និងបង្ហាញច្បាប់ចម្លងនៃអត្ថបទសន្ធិសញ្ញាព្រំដែនវៀតណាម-កម្ពុជាឆ្នាំ១៩៧៩ ដែលនិយាយថា ព្រំដែននឹងត្រូវបានរំលាយ និងធ្វើការកំណត់ជាថ្មី ដែលបានបង្ហាញពីភាពមិនត្រឹមត្រូវ។ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចោទប្រកាន់សមាជិកព្រឹទ្ធសភារូបនេះពីបទក្បត់ជាតិ និងបានចេញបញ្ជាឲ្យចាប់ខ្លួនគាត់។ ក្រោយមក សមាជិកព្រឹទ្ធសភារូបនេះ ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ និងត្រូវបានចោទប្រកាន់ពីបទក្លែងបន្លំឯកសារសាធារណៈ ប្រើប្រាស់ឯកសារសាធារណៈក្លែងក្លាយ និងញុះញង់ឲ្យមានចលាចលក្នុងសង្គម។ អភ័យឯកសិទ្ធិរបស់គាត់មិនត្រូវបានដកហូតទេ ដោយសារអាជ្ញាធរបានចាត់ទុកថា គាត់ត្រូវបានចាប់ខ្លួនក្នុងការប្រព្រឹត្តបទល្មើសជាក់ស្ដែង។

- **លោក គង់ សភា និង លោក ញ៉យ ចំរើន** ជាសមាជិកសភា ត្រូវបានគេទាញទម្លាក់ពីរថយន្តរបស់ពួកគេ ហើយត្រូវគេវាយដំដោយហឹង្សា ខណៈពេលដែលពួកគេកំពុងធ្វើដំណើរចេញពីវិមានរដ្ឋសភានៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥។ នៅពេលនោះ បាតុកម្មមួយប្រឆាំងនឹងគណៈបក្សប្រឆាំង ត្រូវបានរៀបចំឡើងដោយគណៈបក្សកាន់អំណាច កំពុងធ្វើនៅខាងមុខវិមានរដ្ឋសភា។ ទាំងមន្ត្រីសន្តិសុខរដ្ឋសភា ទាំងមន្ត្រីនគរបាលដែលមានវត្តមាននៅទីនោះ មិនបានចាត់វិធានការណាមួយទាំងមុនពេល ក្នុងពេល ឬបន្ទាប់ពីការវាយប្រហារនោះទេ ដូចដែលបានបង្ហាញតាមរយៈខ្សែវីដេអូក្លីបនៃឧប្បត្តិហេតុស្រាប់។ ការវាយប្រហារនេះ បានធ្វើឲ្យសមាជិកសភាទាំងពីររូបនេះរងរបួសធ្ងន់ធ្ងរ។ ការវាយប្រហារនេះ ត្រូវបានរដ្ឋសភាធ្វើការថ្កោលទោស និងបានផ្ដួចផ្ដើមឲ្យមានការស៊ើបអង្កេតដែលឈានទៅចាប់ខ្លួនជនសង្ស័យចំនួនបីរូប នៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៥ បន្ទាប់ពីពួកគេបានចេញមកសារភាពថាបានចូលរួមនៅក្នុងអំពើហិង្សានេះ។ មិនមានវិធានការបន្ថែមណាមួយ ត្រូវបានចាត់ទៅលើអ្នកវាយប្រហារ ឬអ្នកផ្ដើមគំនិតផ្សេងទៀតទេ ទោះបីជាសាមីសមាជិកសភាទាំងនោះ បានដាក់ពាក្យបណ្ដឹងរួចហើយក្ដី និងមានភស្ដុតាងខ្សែវីដេអូយ៉ាងច្បាស់ក្រឡែតអំពីសកម្មភាពវាយប្រហារនេះ បានបង្ហាញឲ្យឃើញពីអត្តសញ្ញាណរបស់អ្នកវាយប្រហារ និងសកម្មភាព ដែលពួកគេកំពុងនិយាយទាក់ទងគ្នាជាមួយអ្នកដទៃទៀតតាមរយៈវិទ្យុទាក់ទងក្ដី។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ គឺអង្គការឃ្លាំមើលសិទ្ធិមនុស្ស(HRW) បានដឹកនាំការស៊ើបអង្កេតទាំងស្រុងក្នុងឧប្បត្តិហេតុនេះ ហើយបានធ្វើការសន្និដ្ឋាន ក្នុងរបាយការណ៍បោះពុម្ពផ្សាយក្នុងខែឧសភា ឆ្នាំ២០១៦ ថាសវនាការ ត្រូវបានរៀបចំឡើងគឺដើម្បីបិទបាំងការទទួលខុសត្រូវចុងក្រោយសម្រាប់បទល្មើសនេះ ជាជាងការលាតត្រដាងវា។

- **លោក សម រង្ស៊ី** មេដឹកនាំគណៈបក្សប្រឆាំង និងជាសមាជិកសភាមួយរូប ត្រូវបានក្លាយជាគោលដៅដោយករណីបណ្ដឹងនៅតុលាការកាន់តែច្រើនឡើងៗដែលចោទប្រកាន់ទៅលើរូបគាត់ គិតចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៥ (រាប់ទាំងសំណុំរឿងក្ដីមួយដែលទាក់ទងនឹងករណីរបស់សមាជិកព្រឹទ្ធសភា លោក ហុង សុខហួរ ដែលបង្ហោះវីដេអូឃ្លីបលើទំព័រហ្វេសប៊ុករបស់គាត់)។ អភ័យឯកសិទ្ធិរបស់គាត់ មិនត្រូវ

បានដកហូតទេ ប៉ុន្តែអាណត្តិសភារបស់គាត់ ត្រូវបានមោឃភាពពាក់ព័ន្ធនឹងសំណុំរឿងបរិហាកេរ្តិ៍លើកទីមួយនៅសាលាដំបូង។ គាត់បានបង្ខំចិត្តធ្វើនិរទេសខ្លួនទៅក្រៅប្រទេសក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ ដើម្បីគេចវេសពីការទទួលទោសជាប់ពន្ធនាគារ។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ លោកនាយករដ្ឋមន្ត្រីបានចេញបំរាមមិនឲ្យលោក សម រង្ស៊ី វិលត្រឡប់ចូលប្រទេសកម្ពុជាវិញ បន្ទាប់ពីគាត់បានប្រកាសពីបំណងប្រាថ្នាវិលត្រឡប់មកវិញពីការនិរទេសខ្លួននៅក្រៅប្រទេស ដើម្បីចូលរួមក្នុងការបោះឆ្នោតនៅថ្ងៃខាងមុខនេះ។

- **លោក អ៊ុំ សំអាន** ជាសមាជិកសភាមួយរូប ត្រូវបានចាប់ខ្លួននៅថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០១៦ នៅពេលដែលគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ ហើយត្រូវបានផ្តន្ទាទោសនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ ឲ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំកន្លះ ពីបទញុះញង់ឲ្យមានអំពើហិង្សា និងការរើសអើង។ យោងតាមអ្នកប្តឹង សំណុំរឿងក្តីនេះកើតមានឡើង បន្ទាប់ពីគាត់បានបង្ហោះមតិយោបល់ និងខ្សែវីដេអូនៅលើហ្វេសប៊ុកក្នុងឆ្នាំ២០១៥ អំពីបញ្ហាព្រំដែនកម្ពុជា-វៀតណាម ក្នុងការអះអាងជាពិសេសថា រដ្ឋាភិបាលបានប្រើប្រាស់ "ផែនទីក្លែងក្លាយ" ដើម្បីកំណត់ព្រំដែន។ អភ័យឯកសិទ្ធិសភារបស់គាត់ មិនត្រូវបានដកទេ។ យោងតាមអ្នកប្តឹង អាជ្ញាធរបានអះអាងថា គាត់ត្រូវបានចាប់ខ្លួនក្នុងបទល្មើសជាក់ស្តែង ដោយសារតែបទល្មើសនេះនៅតែបន្ត ដរាបណាដែលមតិយោបល់របស់គាត់មិនត្រូវបានដកចេញពីហ្វេសប៊ុកទេនោះ (ទោះជាយ៉ាងណាក៏ដោយ តុលាការបានបដិសេធពាក្យសុំធានាឲ្យនៅក្រៅឃុំ ដោយឈរលើហេតុផលថា មានហានិភ័យដែលគាត់អាចនឹងបំផ្លាញភស្តុតាង ដោយដកមតិយោបល់ របស់គាត់ចេញពីហ្វេសប៊ុកប្រសិនជាដោះលែងឲ្យគាត់នៅក្រៅឃុំបណ្តោះអាសន្ននោះ)

- **លោក កឹម សុខា** ជាអនុប្រធានទីមួយនៃរដ្ឋសភាកម្ពុជារហូតដល់ខែតុលា ឆ្នាំ២០១៥ ហើយបច្ចុប្បន្នលោកគឺជាប្រធានគណៈបក្សសង្គ្រោះជាតិ (CNRP) ដែលបានប្រឈមនឹងការបំភិតបំភ័យ និងការយាយីរំខាន ចាប់តាំងពីខែមេសា ឆ្នាំ២០១៥ រាប់ទាំងការគំរាមកំហែងម្តងហើយម្តងទៀត ការវាយប្រហារលើនិវេសនដ្ឋានរបស់គាត់ (ក្នុងខែតុលា ឆ្នាំ២០១៥) គាត់ត្រូវគេដកចេញពីមុខតំណែងជាអនុប្រធានទីមួយនៃរដ្ឋសភា (ក្នុងខែតុលា ឆ្នាំ២០១៥) និងករណី "ស្រីមុំ" គឺជាករណីប្រឆាំងនឹងគាត់ ដែលបាននិងកំពុងបន្តចាប់តាំងពីចុងខែកុម្ភៈ ឆ្នាំ២០១៦ មក។ ទោះបីជាអភ័យឯកសិទ្ធិរបស់គាត់មិនត្រូវបានដកក្តី ក៏ការប៉ុនប៉ងចាប់ខ្លួនលោក កឹម សុខា ត្រូវបានធ្វើឡើងនៅក្នុងខែឧសភា ឆ្នាំ២០១៦ ហើយគាត់បានស្នាក់នៅមិនចេញទៅណាជាច្រើនខែក្នុងទីស្នាក់ការកណ្តាលរបស់គណៈបក្សសង្គ្រោះជាតិ ចាប់តាំងពីពេលនោះមក ក្រោមការឃុំខ្លួនក្នុងផ្ទះតាមព្រឹត្តន័យ នេះបើយោងតាមអ្នកប្តឹង។ លោក កឹម សុខា ក៏ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលប្រាំមួយខែផងដែរ គឺនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៦ ចំពោះការបដិសេធមិនចូលខ្លួនតាមដីកាកោះ ដើម្បីសាកសួរ។

- **អ្នកស្រី ថាក់ ឡានី** ជាសមាជិកព្រឹទ្ធសភាមួយរូប ត្រូវបានចោទប្រកាន់ដោយលោកនាយករដ្ឋមន្ត្រីពីបទបង្កាច់បង្ខូច និងការញុះញង់ នៅដើមខែសីហា ឆ្នាំ២០១៦ បន្ទាប់ពីមានខ្សែវីដេអូមួយត្រូវបានគេបង្ហោះតាមអនឡាញ ដែលក្នុងនោះទំនងជាចង់និយាយថាលោកនាយករដ្ឋមន្ត្រីបានចូលរួមពាក់ព័ន្ធក្នុងករណីឃាតកម្មលើលោក កែម ឡី អ្នកវិភាគនយោបាយ។ យោងទៅតាមអ្នកប្តឹង សមាជិកព្រឹទ្ធសភារូបនេះបានបដិសេធថាគាត់មិនបានធ្វើសេចក្តីថ្លែងការណ៍នេះទេ ហើយអះអាងថា ខ្សែវីដេអូនេះ ត្រូវបានគេកែសម្រួល។ សមាជិកព្រឹទ្ធសភារូបនេះ ត្រូវបានតុលាការកោះហៅពីរដងឲ្យបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា មុនពេលអភ័យឯកសិទ្ធិសភារបស់អ្នកស្រីត្រូវបានដកនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦។ អ្នកស្រី ឡានី កំពុងស្ថិតក្នុងការនិរទេសខ្លួន។

*ដោយរំលឹក*នូវចំណុចខាងក្រោមចំពោះកិច្ចសន្ទនានយោបាយ និងដំណើរទស្សនកិច្ចរបស់គណៈកម្មាធិការក្នុងឆ្នាំ២០១៦ មកកាន់ប្រទេសកម្ពុជា៖

- កិច្ចព្រមព្រៀងនយោបាយនេះ បានបញ្ចប់វិបត្តិក្រោយការបោះឆ្នោត ឆ្នាំ២០១៣ និងបានបង្កើតយន្តការមួយសម្រាប់កិច្ចសន្ទនារវាងជាគណបក្សនយោបាយធំទាំងពីរដែលមានតំណាងនៅក្នុងរដ្ឋសភា ដែលគេស្គាល់ថាជា "វប្បធម៌សន្ទនា"។ វប្បធម៌សន្ទនាត្រូវបានគណបក្សទាំងពីរចាត់ទុកថាមានសារសំខាន់ដើម្បីបញ្ចប់វប្បធម៌ហិង្សាជាទូទៅ។ វប្បធម៌សន្ទនានេះ បានបើកលំហបន្ថែមទៀតសម្រាប់ការសន្ទនានយោបាយនៅក្នុងស្ថាប័នសភា និងបានអនុញ្ញាតឲ្យគណបក្សទាំងនេះ សម្រេចបាននូវវឌ្ឍនភាពលើបញ្ហាមួយចំនួនដែលជាផលប្រយោជន៍ជាតិនៅចន្លោះខែកក្កដា ឆ្នាំ២០១៤ និងពាក់កណ្តាល ឆ្នាំ២០១៥។ ទោះជាយ៉ាងណាក៏ដោយ វប្បធម៌សន្ទនានេះបានបរាជ័យក្នុងការលើកឡើង និងដោះស្រាយរឿងក្តីបច្ចុប្បន្ននេះ
- ក្នុងខែកុម្ភៈ ឆ្នាំ២០១៥ គណៈកម្មាធិការនេះ បានធ្វើ "ទស្សនកិច្ចមួយជាជម្រើសចុងក្រោយ" មកកាន់ប្រទេសកម្ពុជា បន្ទាប់ពីបានទុកពេលឲ្យម្តងហើយម្តងទៀតឲ្យភាគីទាំងពីរស្វែងរកដំណោះស្រាយតាមរយៈការចរចា។ របាយការណ៍ចុងក្រោយនៃដំណើរទស្សនកិច្ចនេះ បានធ្វើការសន្និដ្ឋានថាសមាជិកសភា បាន - និងបន្តក្លាយជា - ជនរងគ្រោះពីការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិជាមូលដ្ឋានរបស់ពួកគេ។ ពួកគេត្រូវបានរារាំងមិនឲ្យដើរតួនាទីរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពជាសមាជិកសភា និងសមាជិកគណបក្សប្រឆាំងដោយសេរី ដោយគ្មានការភ័យខ្លាចការធ្វើទុក្ខបុកម្នេញ
- រដ្ឋសភាកម្ពុជាបានចែករំលែកទស្សនៈផ្លូវការរបស់ខ្លួននៅក្នុងលិខិតចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦។ រដ្ឋសភានេះ បានបដិសេធថាមានការរំលោភណាមួយលើសិទ្ធិមនុស្សត្រូវបានប្រព្រឹត្តនៅក្នុងរឿងក្តីបច្ចុប្បន្នទេ ហើយបានអះអាងថាសាមីតំណាងរាស្ត្រគណបក្សប្រឆាំងទាំងអស់គឺជាឧក្រិដ្ឋជន ដែលត្រូវតែទទួលទោសតាមច្បាប់។ ដូច្នោះ នេះគឺជាកិច្ចការរបស់តុលាការសុទ្ធសាធសម្រាប់តុលាការកម្ពុជាក្នុងការសម្រេច ហើយថានេះមិនមែនជាបញ្ហានយោបាយដែលអាចត្រូវបានដោះស្រាយតាមរយៈវប្បធម៌សន្ទនា ព្រោះថាកិច្ចសន្ទនានយោបាយមិនអាចជំនួស ឬបំពានច្បាប់បានឡើយ

*ដោយពិចារណាថា* មិនមានការរីកចម្រើនដែលសម្រេចបាន លើករណីទាំងឡាយដែលស្ថិតក្រោមការពិនិត្យឬលើការបន្តនៃកិច្ចសន្ទនានយោបាយក្នុងន័យស្ថាបនា ហើយថាស្ថានភាពនេះបានធ្លាក់ដុនដាបខ្លាំងថែមទៀតនៅក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ដូចដែលបានបង្ហាញដោយស្ថានការណ៍វិវឌ្ឍថ្មីៗគួរឲ្យបារម្ភដូចខាងក្រោមនេះ បានកើតឡើងចាប់តាំងពីសម័យប្រជុំលើកទី១៣៥ របស់សហភាពអន្តរសភា(IPU) នេះបើតាមអ្នកប្តឹង ៖

- អង្គរក្សបីនាក់ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលបួនឆ្នាំ (រាប់ទាំងរយៈពេលព្យួរទោសបីឆ្នាំ) បន្ទាប់ពីការសារភាពថាបានវាយដំលើលោក គង់ សភា និង លោក ញ៉ូយ ចំរើន ត្រូវបានដោះលែងពីពន្ធនាគារ បន្ទាប់ពីបានជាប់ពន្ធនាគារតែមួយឆ្នាំ។ ពួកគេត្រូវបានធ្វើសមាហរណកម្មភ្លាមៗទៅក្នុងអង្គភាពអង្គរក្សរបស់លោកនាយករដ្ឋមន្ត្រី និងត្រូវបានលោកនាយករដ្ឋមន្ត្រីតម្លើងឋានន្តរសក្តិ។ សមាជិកសភាទាំងពីរនេះបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការដែលសាលាដំបូងផ្តន្ទាទោសស្រាលមិនត្រូវបានចាត់ការទេរហូតមកទល់ពេលនេះ។ អ្នកវាយប្រហារផ្សេងទៀត ដែលមិនត្រូវបានធ្វើការស៊ើបអង្កេត ឬដាក់ឲ្យទទួលខុសត្រូវឡើយ។ មិនត្រឹមតែមិនសង្ស័យពីការរៀបចំ និងអ្នកញុះញង់តែ បើទោះជាមានភស្តុតាងច្បាស់លាស់ហើយក្តី
- នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ បណ្តឹងឧទ្ធរណ៍របស់លោក កឹម សុខា ត្រូវបានតុលាការច្រានចោល។ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៦ គាត់ត្រូវបានព្រះមហាក្សត្រផ្តល់ការលើកលែងទោសចំពោះបទដែលគាត់ខកខានចូលបង្ហាញខ្លួននៅមុខតុលាការ។ ទំនាក់ទំនងរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិដំបូងឡើយមានលក្ខណៈវិជ្ជមានបន្ថែមទៀតបន្ទាប់ពីការលើកលែងទោសលោក កឹម សុខា។ គណបក្សសង្គ្រោះជាតិបញ្ចប់ពហិការរបស់ខ្លួន និងបានចូលធ្វើការងារក្នុងរដ្ឋសភាវិញ។ នៅថ្ងៃទី៦ ខែ

ធ្នូ ឆ្នាំ ២០១៦ លោកនាយករដ្ឋមន្ត្រីបានផ្តល់ឋានៈឲ្យលោក កឹម សុខា ប្រធានក្រុមភាគតិចនៅក្នុងរដ្ឋសភា (ជំនួសលោក សម រង្ស៊ី)។ កិច្ចដំណើរការនីតិវិធីដ៏សំខាន់របស់តុលាការនៅក្នុងករណី "ស្រីមុំ" ទោះជាយ៉ាងណាក៏ដោយ នៅតែបន្ត។ ការសម្រេចចិត្តជាប្រវត្តិសាស្ត្រមួយនៃក្រុមការងាររបស់អង្គការសហប្រជាជាតិស្តីពីការឃុំខ្លួនតាមទំនើងចិត្ត ត្រូវបានអនុម័តនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៦ បានសន្និដ្ឋានថា ការឃុំខ្លួនសមាជិកសង្គមស៊ីវិលដែលបានចាប់ខ្លួនភ្ជាប់ទៅនឹងករណី "ស្រីមុំ" គឺធ្វើឡើងតាមទំនើងចិត្ត

- នៅចុងខែមករា ឆ្នាំ២០១៧ លោក កឹម សុខា ត្រូវបានដកហូតឋានៈជាប្រធានក្រុមភាគតិច បន្ទាប់ពីរដ្ឋសភាបានធ្វើវិសោធនកម្មវិធានផ្ទៃក្នុងរបស់ខ្លួន នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៦ តាមសេចក្តីណែនាំរបស់នាយករដ្ឋមន្ត្រី។ បទប្បញ្ញត្តិនេះ បង្កើតប្រធានក្រុមភាគតិចមួយនៅក្នុងរដ្ឋសភា និងឋានៈផ្លូវការទៅឲ្យគណបក្សប្រឆាំងត្រូវបាននិរាករណ៍។ ពួកគេបានស្ថិតក្នុងចំណោមលទ្ធផលវិជ្ជមាននៃកិច្ចព្រមព្រៀងនយោបាយឆ្នាំ២០១៤ និងបានបង្កើតមូលដ្ឋានច្បាប់សម្រាប់ការវប្បធម៌សន្ទនា

- នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៧ លោក សម រង្ស៊ី បានលាលែងពីតំណែងរបស់លោកជាមេដឹកនាំគណបក្សសង្គ្រោះជាតិ ដើម្បីការពារគណបក្សពីការត្រូវរំលាយដោយអនុលោមតាមកំណែទម្រង់ច្បាប់ ដើម្បីធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ឆ្នាំ១៩៩៧។ លោក កឹម សុខា បានជំនួសតំណែងជាប្រធានគណបក្សសង្គ្រោះជាតិ បន្ទាប់ពីសមាជគណបក្សសង្គ្រោះជាតិ បានធ្វើឡើងនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧។ អ្នកស្រី មូរ សុខហួរ ត្រូវបានជ្រើសតាំងជាអនុប្រធាននៅពេលនោះ រួមជាមួយលោក អេង ឆៃអ៊ាង និងលោក ប៉ុល ហំម

- នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧ វិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយឆ្នាំ១៩៩៧ ត្រូវបានអនុម័តបន្ទាប់ពីត្រូវបានដំណើរការយ៉ាងឆាប់រហ័សដោយសភាកម្ពុជា តាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី។ ច្បាប់វិសោធនកម្មនេះផ្តល់អំណាចដែលមិនធ្លាប់មានពីមុនមកទៅឲ្យអង្គនីតិប្រតិបត្តិ និងតុលាការ ដើម្បីព្យួរ និងរំលាយគណបក្សនយោបាយ។ ច្បាប់នេះ ហាមប្រាមជនដែលតុលាការផ្តន្ទាទោសព្រហ្មទណ្ឌ (រាប់ទាំងបទលហុផងដែរ) - ដូចជាលោក សម រង្ស៊ី - មិនឲ្យកាន់មុខតំណែងជាន់ខ្ពស់នៅក្នុងគណបក្សនយោបាយ។ ច្បាប់នេះ ហាមប្រាមផងដែរ ដល់គណបក្សនយោបាយមិនឲ្យទទួលថវិកាបរទេស។ អនុលោមតាមច្បាប់ដែលបានធ្វើវិសោធនកម្មនេះ ប្រសិនបើត្រូវបានផ្តន្ទាទោសពីបទព្រហ្មទណ្ឌណាមួយ មេដឹកនាំគណបក្សមួយនោះ នឹងត្រូវបានហាមប្រាមមិនឲ្យធ្វើសកម្មភាពនយោបាយណាមួយសម្រាប់រយៈពេលប្រាំឆ្នាំ ហើយគណបក្សនយោបាយរបស់គាត់នឹងត្រូវបានរំលាយចោលដោយសាលដីកាតុលាការកំពូល។ កង្វល់ជាច្រើនត្រូវបានសម្តែងនិងបានពាំនាំកង្វល់នេះប្រាប់មកគណៈកម្មាធិការទាក់ទងនឹងបទប្បញ្ញត្តិនៃវិសោធនកម្មនេះ ដែលត្រូវបានប្រើប្រាស់ពាក្យពេចន៍មិនច្បាស់លាស់ និងមានសភាពចម្លែកជាមួយនឹងការរឹតត្បិតដែលបានទទួលយកទៅលើសិទ្ធិសេរីភាពក្នុងការបង្កើត សមាគមក្រោមច្បាប់អន្តរជាតិ (ជាពិសេសជាមួយនឹងលក្ខខណ្ឌតម្រូវនៃភាពចាំបាច់និងសមាមាត្រភាពនេះ) ដូចបានឆ្លុះបញ្ចាំងនៅក្នុងការវិភាគផ្នែកច្បាប់ដែលបានចេញផ្សាយនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ ដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

- បន្ទាប់ពីការចូលជាធរមាននៃវិសោធនកម្មនេះ អាជ្ញាធរកម្ពុជាបានជំទាស់នឹងថ្នាក់ដឹកនាំថ្មីដែលបានជាប់ឆ្នោតនៃគណបក្សសង្គ្រោះជាតិ។ សំណើសុំចុះបញ្ជីឡើងវិញរបស់គណបក្សសង្គ្រោះជាតិ តាមលក្ខខណ្ឌតម្រូវក្រោមច្បាប់ដែលបានធ្វើវិសោធនកម្មនេះ ដូច្នេះមិនត្រូវបានអនុញ្ញាតដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឡើយ។ គណបក្សប្រជាជនកម្ពុជាបានគំរាមប្តឹងគណបក្សសង្គ្រោះជាតិពីបទបរិហារកេរ្តិ៍មកលើខ្លួន និងញុះញង់ឲ្យមានការចលាចលសង្គម ដោយសារតែការជ្រើសរើសយកពាក្យស្លោកយុទ្ធនាការបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ ("ប្តូរមេឃុំបំរើបក្ស ដាក់មេឃុំបំរើរាស្ត្រ")។ បច្ចុប្បន្ន គណ

បក្សសង្គ្រោះជាតិមិនត្រូវបានទទួលស្គាល់ថាជាគណបក្សនយោបាយទេនៅពេលដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតកំពុងដំណើរការដើម្បីបញ្ចប់បញ្ជីបេក្ខជនដែលបានទទួលសម្រាប់ការបោះឆ្នោតឃុំ/សង្កាត់ (ដែលរាប់ទាំងបេក្ខជនគណបក្សសង្គ្រោះជាតិ)។ ស្ថានភាពអាប់អួរផ្នែកច្បាប់មួយបន្ថែមទៀត នៅតែបន្តបោកបក់មកលើថ្នាក់ដឹកនាំថ្មីនៃគណបក្សសង្គ្រោះជាតិ ជាមួយនឹងកិច្ចដំណើរការនីតិវិធីដែលកំពុងបន្តមានចំពោះលោក កឹម សុខា និងអ្នកស្រី មួរ សុខហួរ។ ស្ថានភាពនេះ អាចនឹងបណ្តាលឲ្យមានការព្រួយ និងការរំលាយគណបក្សសង្គ្រោះជាតិ អនុលោមតាមច្បាប់គណបក្សនយោបាយដែលបានធ្វើវិសោធនកម្ម និងដកហូតសិទ្ធិចូលរួមនៃថ្នាក់ដឹកនាំថ្មីរបស់ខ្លួនក្នុងសកម្មភាពនយោបាយសម្រាប់រយៈពេលប្រាំឆ្នាំ

ស្ថានការណ៍វិវឌ្ឍគួរឲ្យកត់សម្គាល់ដូចខាងក្រោមនេះបានកើតឡើងនៅក្នុងករណីផ្សេងទៀតស្ថិតក្រោមការត្រួតពិនិត្យ៖

- មានបណ្តឹងតុលាការថ្មីៗបានបន្តដាក់ប្រឆាំងនឹងលោកសមរង្ស៊ី។ មានការផ្តន្ទាទោសចំនួនបួនបន្ថែមទៀតត្រូវបានសម្រេច ចំពោះកិច្ចដំណើរការនីតិវិធីពីមុនៗ។ លោកត្រូវបានគេរកឃើញថាមានពិរុទ្ធភាព នៅក្នុងគ្រប់ករណីទាំងអស់។ ទោសដែលតុលាការបានកាត់ឲ្យគាត់ជាប់ពន្ធនាគារមានសរុប ប្រមាណជាប្រាំបីឆ្នាំ និងពិន័យធ្ងន់ធ្ងរ នៅដើមខែមេសា ឆ្នាំ២០១៧
- សមាជិកព្រឹទ្ធសភា លោក ហុង សុខហួរ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលប្រាំពីរឆ្នាំ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់គាត់បានស្នើឲ្យមានការវិភាគអ៊ីនធឺណិតដោយអ្នកជំនាញឯករាជ្យ និងឲ្យមានការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតនៅក្នុងបន្ទប់សវនាការ ដើម្បីបង្ហាញចៅក្រមពីរបៀបដែលគាត់បានទាញយកសំណៅដែលមានវិវាទនៃឯកសារសន្ធិសញ្ញាព្រំដែនវៀតណាម-កម្ពុជាឆ្នាំ១៩៧៩ ពីអ៊ីនធឺណិតនោះ មិនត្រូវបានតុលាការអនុញ្ញាតនៅក្នុងពេលសវនាការទេ។ ដំណើរការសវនាការនៅសាលាឧទ្ធរណ៍នឹងគ្រោងធ្វើនៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៧
- សមាជិកព្រឹទ្ធសភា អ្នកស្រី ថាក់ ឡានី ត្រូវបានតុលាការផ្តន្ទាទោសកំបាំងមុខដាក់ពន្ធនាគាររយៈពេល១៨ ខែនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ បន្ទាប់ពីគាត់បាននិរទេសខ្លួន។ នៅក្នុងពេលសវនាការ មេធាវីគាត់បានបន្តអះអាងថា វីដេអូនេះត្រូវបានគេកែសម្រួល ហើយថាអ្នកស្រី ថាក់ ឡានី មិនបានធ្វើសេចក្តីថ្លែងការណ៍ចោទប្រកាន់ឡើយ ខណៈសាក្សីដាក់បន្ទុកបានអះអាងផ្ទុយពីនេះ។ ប្រភពដើមនៃវីដេអូឃ្លីបនេះមិនបានបង្ហាញឲ្យឃើញច្បាស់ទេ នេះបើយោងតាមអ្នកប្តឹង។ ប្រធានចៅក្រមជំនុំជម្រះត្រូវបានគេអះអាងថា បានបញ្ឈប់មេធាវីការពារក្តី នៅពេលដែលគាត់ចាប់ផ្តើមសួរសាក្សីដាក់បន្ទុកអំពីអ្នកដែលបានថតវីដេអូនេះ

*ពិចារណា*ពីលិខិតឆ្លងឆ្លើយ និងសំណើថ្មីសម្រាប់ព័ត៌មានបានពាំនាំដោយអគ្គលេខាធិការសហភាពអន្តរសភា (IPU) ក្នុងនាមគណៈកម្មាធិការនៅថ្ងៃទី១២ និងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៦ និងថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ ដែលមិនមានការឆ្លើយតបពីអាជ្ញាកម្ពុជាទេ ចាប់តាំងពីសម័យប្រជុំលើកទី១៣៥ នៃសហភាពអន្តរសភា (IPU)

*ពិចារណាថា* ចាប់តាំងពីការដាក់ពាក្យបណ្តឹងដំបូងនៅខែកក្កដា ឆ្នាំ២០១៤ មានលិខិតផ្លូវការមួយចំនួនត្រូវបានផ្ញើជូនដោយសហភាពអន្តរសភា(IPU) ស្នើសុំព័ត៌មានជាក់លាក់ ឯកសារ និងសេចក្តីសង្កេតជាផ្លូវការពីអាជ្ញាធរសភា ចំពោះរឿងក្តីបច្ចុប្បន្ននេះ។ ទោះយ៉ាងណាក៏ដោយ អាជ្ញាធរកម្ពុជាបានចែករំលែកការឆ្លើយតបជាលាយលក្ខអក្សរចំនួនបីតែប៉ុណ្ណោះនៅក្នុងរយៈពេលបីឆ្នាំ ក្នុងនោះលិខិតចុងក្រោយបង្អស់ចុះខែតុលា ឆ្នាំ២០១៦។ ការឆ្លើយតបទាំងនោះមានសារៈប្រយោជន៍ ប៉ុន្តែបានត្រឹមតែ

ដោះស្រាយបញ្ហានិងផ្តល់ព័ត៌មានដែលបានសំណើសុំមួយចំនួនតែប៉ុណ្ណោះ។ អាជ្ញាធរបានខកខានក្នុងការបន្តផ្តល់ព័ត៌មានឲ្យគណកម្មាធិការដឹងអំពីស្ថានការណ៍វិវឌ្ឍថ្មីៗ ដូចជាសាលក្រមតុលាការដែលបានសម្រេចលើករណីទាំងនេះ និងការផ្តល់ឯកសារគាំទ្រ ដូចជាច្បាប់ចម្លងនៃសេចក្តីសម្រេចរបស់តុលាការជាដើម។

*ដោយរំលឹកថា*មានចំនួនរដ្ឋនិងអង្គការអន្តរជាតិកាន់តែកើនឡើង រាប់ទាំងអង្គការសហប្រជាជាតិ បានសម្តែងកង្វល់យ៉ាងខ្លាំងអំពីការធ្លាក់ចុះនៃស្ថានភាពសិទ្ធិមនុស្ស និងនយោបាយនៅកម្ពុជា ជាពិសេស បរិយាកាសកាន់តែអាក្រក់សម្រាប់អ្នកនយោបាយគណបក្សប្រឆាំង និងសកម្មជនសិទ្ធិមនុស្ស ដោយសារតែមានការកើនឡើងនៃការចោទប្រកាន់ទាក់ទងនឹងរឿងនយោបាយ ការយាយីផ្នែកតុលាការ និងអំពើហឹង្សា។ រដ្ឋនិងអង្គការអន្តរជាតិទាំងនេះ រាប់អង្គការសហប្រជាជាតិ បានជំរុញឲ្យរដ្ឋាភិបាលកម្ពុជាធានាឲ្យមានការគោរពសិទ្ធិមនុស្សឲ្យបានពេញលេញ រាប់ទាំងសេរីភាពក្នុងការបញ្ចេញមតិ ការបង្កើតសមាគម និងការជួបប្រជុំ ហើយត្រូវប្រកាន់ខ្ជាប់យ៉ាងតឹងរឹងចំពោះបទដ្ឋានអន្តរជាតិស្តីពីការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ ធ្វើដូច្នេះដើម្បីធានាថា ច្បាប់ត្រូវបានអនុវត្តដោយគ្មានការរើសអើងទោះជាដោយហេតុផលអ្វីក៏ដោយ។ រដ្ឋនិងអង្គការអន្តរជាតិទាំងនេះ បានអំពាវនាវឲ្យមានការបន្តជាបន្ទាន់នូវ កិច្ចសន្ទនានយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ និងសម្រាប់ការបង្កើតបរិយាកាសនយោបាយមួយ ដែលក្នុងនោះគណបក្សប្រឆាំង និងសង្គមស៊ីវិលទាំងអស់អាចអនុវត្តមុខងារសកម្មភាពរបស់ខ្លួនបានដោយសេរី និងដោយគ្មានការភ័យខ្លាចមានការចាប់ខ្លួន ឬមានការធ្វើទុក្ខបុកម្នេញ ដើម្បីឲ្យប្រទេសកម្ពុជាអាចរៀបចំការ បោះឆ្នោតដោយសេរី និងយុត្តិធម៌ ដែលនឹងធានាបាននូវភាពស្របច្បាប់នៃរដ្ឋាភិបាលថ្មី។

*ដោយពិចារណា*លើរបាយការណ៍ដែលមានចំណងជើងថា "ការដើរថយក្រោយខាងលទ្ធិប្រជាធិបតេយ្យ - ការវាយប្រហារលើសមាជិកសភានិងការគំរាមកំហែងចំពោះស្ថាប័នរបស់កម្ពុជា" ដែលបានចេញផ្សាយនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ ដោយសមាជិកសភាអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងការរកឃើញ និងអនុសាសន៍ដែលធ្វើឡើងដោយការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស(UNOHCHR) នៅក្នុងសេចក្តីវិភាគផ្នែកច្បាប់លើច្បាប់ស្តីពីគណបក្សនយោបាយដែលទើបបានធ្វើវិសោធនកម្ម ហើយដែលបានចេញផ្សាយនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧

*ដោយពិចារណាថា* ព័ត៌មានខាងក្រោមនេះ ត្រូវបានចែករំលែកនៅក្នុងអំឡុងពេលសវនាការដាច់ដោយឡែកចំនួនពីរ ដែលបានធ្វើឡើងនៅក្នុងអំឡុងពេលនៃសម័យប្រជុំលើកទី១៣៦ របស់សភាពអន្តរសភា(IPU) ជាមួយគណៈប្រតិភូកម្ពុជាមួយផ្សេង និងជាមួយតំណាងគណបក្សសង្គ្រោះជាតិមួយផ្សេងទៀត ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការ ដើម្បីបន្តស្តាប់ភាគីទាំងពីរ ក្នុងលក្ខណៈជាប្រព័ន្ធមួយ ដើម្បីលើកកម្ពស់កិច្ចពិភាក្សា៖

- ភាគីទាំងពីរបានបញ្ជាក់ជាថ្មីអំពីជំហពីមុនរបស់ខ្លួន លើករណីមួយៗ ហើយមិនអាចរាយការណ៍ពីការរីកចំរើនណាមួយពិតប្រាកដ។ ដំបូងបំផុត ពួកគេបានសម្តែងនូវការភ័យខ្លាច និងកង្វល់អំពីស្ថានភាពសន្តិសុខទូទៅនៅកម្ពុជានៅមុនថ្ងៃបោះឆ្នោតដ៏សំខាន់ ដែលអាចបណ្តាលឲ្យស្ថានការណ៍នយោបាយប្រែប្រួលដែលមិនធ្លាប់មានចាប់តាំងពីការបញ្ចប់សង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ប្រសិនជាគណបក្សសង្គ្រោះជាតិឈ្នះការបោះឆ្នោត។ ស្ថានភាពមិនធ្លាប់មានពីមុនមកនេះ គឺជាដើមចមនៃការភ័យខ្លាចថាកម្ពុជាអាចនឹងវិលត្រឡប់ទៅស្ថានភាពនៃអំពើហិង្សាដូចពេលកន្លងមក ដោយសារតែភាពតានតឹងផ្នែកនយោបាយឡើងខ្ពស់

- គណៈប្រតិភូកម្ពុជាដែលចូលរួមក្នុងសម័យប្រជុំលើកទី១៣៦ របស់សភាពអន្តរសភា(IPU) បានអះអាងជាថ្មីអំពីមូលហេតុទាំងនេះថា អាទិភាពកំពូលសម្រាប់អាជ្ញាធរកម្ពុជា គឺធានាសន្តិភាព និងបង្ការទប់ស្កាត់ភាពចលាចលក្នុងសង្គមឲ្យខាងតែបាន។ តាមទស្សនៈរបស់ពួកគេ ស្ថិរភាពនយោបាយនឹងនាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ចនិងកើនឡើងថែមទៀតនូវការគោរពសិទ្ធិមនុស្សក្នុងពេលវេលាសមស្រប។ ការរីកចម្រើនគួរឲ្យកត់សម្គាល់មានរួចហើយក្នុងទិសដៅនេះនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ គណៈប្រតិភូបានបញ្ជាក់ជាថ្មីថា ដូច្នេះ គណបក្សប្រឆាំងគួរតែបញ្ឈប់ "ចាក់សាំងលើភ្លើង" ហើយប្រកាន់ជំហរមួយបែបស្ថាបនាថែមទៀត ហើយលោក សម រង្ស៊ី គួរតែ "ធ្វើចិត្តឲ្យត្រជាក់"។ គណៈប្រតិភូបានចាត់ទុកថាចាប់តាំងពីការលាឈប់ពីតំណែងរបស់គាត់មក ថ្នាក់ដឹកនាំថ្មីនៃគណបក្សសង្គ្រោះជាតិ មានការថយចុះនូវវោហាសាស្ត្រ ហើយបរិយាកាសបានល្អប្រសើរឡើង។ គណៈប្រតិភូបានគូសបញ្ជាក់ថាពួកគេត្រូវការធ្វើការជាមួយគ្នា ហើយថាស្ថានភាពនេះនឹងប្រសើរឡើងបន្ទាប់ពីការបោះឆ្នោត។ ពួកគេ
  បានអះអាងថាកិច្ចសន្ទនានយោបាយគឺជាផ្នែកបរិយាប័នមួយនៃគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ហើយការនេះមិនដែលបានបញ្ឈប់ឡើយនៅក្នុងគំនិតរបស់ពួកគេ។ គណៈប្រតិភូបានអះអាងថាកម្ពុជាជានិច្ចកាលតែងតែបានសហការជាមួយគណៈកម្មាធិការ ហើយកង្វះការឆ្លើយតបជាលាយលក្ខអក្សរបណ្តាលមកពីការយល់ច្រឡំ បញ្ហាប្រាស្រ័យទាក់ទង និងកង្វះពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើការឆ្លើយតប
- អ្នកស្រី ជូឡុង ស៊ូមូរ៉ា បានគូសបញ្ជាក់នៅក្នុងអំឡុងពេលសវនាការថា កង្វល់ពីខាងដើមទាក់ទងទៅនឹងការរំលោភសិទ្ធិជាមូលដ្ឋានខាងសេរីភាពក្នុងការបញ្ចេញមតិយោបល់ ការបង្កើតសមាគម និងការជួបប្រជុំដែលនៅមិនទាន់ដោះស្រាយបាននៅឡើយទេ។ បរិយាកាសនយោបាយទូទៅនាពេលបច្ចុប្បន្នមិនអំណោយផលសម្រាប់ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ទេ។ លោក សម រង្ស៊ី ត្រូវបានគេផាត់ចេញពីមុខតំណែងបន្ទាប់ពីការធ្វើវិសោធនកម្មច្បាប់គណបក្សនយោបាយ។ ទាំងគណបក្សកាន់អំណាចទាំងអាជ្ញាធរមិនមានសិទ្ធិក្រោមច្បាប់អន្តរជាតិ និងគោលការណ៍ប្រជាធិបតេយ្យ ក្នុងការជ្រើសរើសអ្នកដែលខ្លួនអាចប្រកួតប្រជែងនៅក្នុងការបោះឆ្នោតនៅថ្ងៃខាងមុខទេ ហើយជាក់ស្តែងករណីនេះកើតមានហើយនាពេល បច្ចុប្បន្ននេះ។ មិនមានការរីកចម្រើនទេចាប់តាំងពីការរៀបចំក្បាលម៉ាស៊ីនដឹកនាំថ្មីរបស់គណបក្សសង្គ្រោះជាតិ ដោយសារថាថ្នាក់ដឹកនាំថ្មីរូបនេះ នៅមិនទាន់បានជម្រះចេញនូវការចោទប្រកាន់ពីបទព្រហ្មទណ្ឌដែលមិនទាន់សម្រេច។ គណបក្សសង្គ្រោះជាតិ មានកង្វល់ថាគណបក្សនេះអាចនឹងត្រូវបានរំលាយនៅថ្ងៃណាមួយដោយអនុលោមតាមច្បាប់គណបក្សនយោបាយបានធ្វើវិសោធនកម្ម។ នេះនឹងអាចប្រហាក់ប្រហែលគ្នាទៅនឹងការធ្វើមោឃភាពការបោះឆ្នោតតាមរយៈប្រកួតប្រជែងប្រជាប្រិយភាពលើសមាជិកសភា   គណបក្សសង្គ្រោះជាតិ ចំនួន ៦៦ រូបដែលបានជាប់ឆ្នោតក្នុងឆ្នាំ ២០១៣ និងត្រឡប់ទៅប្រព័ន្ធគណបក្សតែមួយ នៅមុនការបោះឆ្នោតឃុំសង្កាត់។ ដំណោះស្រាយតែមួយគត់គឺត្រូវរកច្រកចេញ តាមរយៈការសន្ទនា ការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស និងគោលការណ៍ប្រជាធិបតេយ្យសំខាន់ៗដោយមានការជួយឧបត្ថម្ភពីកិច្ចសម្រុះសម្រួលជាអន្តរជាតិ។ គណបក្សកាន់អំណាចមិនគួរខ្លាចលទ្ធភាពនៃការបាត់បង់អំណាចសម្រាប់ប៉ុន្មានឆ្នាំនេះទេ ផ្ទុយទៅវិញគេគួរតែចាត់ទុកថាជាការអនុវត្តធម្មតាមួយ ក្នុងរបបប្រជាធិបតេយ្យ ហេតុនេះ មានលទ្ធផលជាវិជ្ជមាននៃកំណែទម្រង់ប្រជាធិបតេយ្យដែលបាន    អនុវត្តនៅកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ការធានាពិតជាអាចត្រូវបានចរចារ ហើយរៀបចំឲ្យមានការធានាឲ្យបាននូវអន្តរកាលមួយដោយរលូន និងសន្តិវិធីប្រសិនជាមានការជំនួសអំណាចនយោបាយ ដើម្បីបញ្ចៀសបាននូវការសងសឹកផ្នែកនយោបាយដែលកើតមាននាពេលក្រោយ និងកាត់បន្ថយការភ័យខ្លាចដែលមានស្រាប់

*ដោយចងចាំ* នូវចំណុចខាងក្រោមនេះ ចំពោះកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ក្នុងការគោរព ការ

ការពារ និងការលើកកម្ពស់សិទ្ធិមនុស្សជាមូលដ្ឋាន៖

- ក្នុងនាមជារដ្ឋភាគីមួយនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កម្ពុជាមានកាតព្វកិច្ចគោរពបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមទាំងសិទ្ធិជាមូលដ្ឋានខាងសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការជួបប្រជុំ សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលធ្វើឡើងដោយតុលាការមួយឯករាជ្យនិងមិនលំអៀង និងដើម្បីចូលរួមក្នុងកិច្ចការសាធារណៈ។
- បន្ទាប់ពីវដ្តទី២ នៃការពិនិត្យឡើងវិញតាមកាលកំណត់ជាសកល (UPR) របស់កម្ពុជា ដែលបានធ្វើឡើងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅឆ្នាំ២០១៤ អាជ្ញាធរកម្ពុជា បានទទួលយកអនុសាសន៍ទាំងនោះ ដើម្បី "លើកកម្ពស់បរិយាកាសអំណោយផល និងមានសុវត្ថិភាព ដែលអនុញ្ញាតឲ្យបុគ្គលនានា និងក្រុមទាំងឡាយ អាចអនុវត្តសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការបង្កើតសមាគមនិងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងបញ្ចប់ការឃាយឃី ការគំរាមកំហែង ការចាប់ខ្លួនតាមទំនើងចិត្ត និងការវាយប្រហារលើរូបកាយ ជាពិសេសនៅក្នុងបរិបទនៃការធ្វើបាតុកម្មដោយសន្តិវិធី" និង "ចាត់វាល់វិធានការចាំបាច់នានា ដើម្បីធានាឯករាជ្យភាពរបស់តុលាការ ដោយគ្មានការគ្រប់គ្រង ឬការជ្រៀតជ្រែកខាងនយោបាយ" (របាយការណ៍របស់ក្រុមការងារ UPR នៃប្រទេសកម្ពុជា A/HRC/26/16)។

*ដោយចងចាំក្នុងចិត្តផងដែរ* នូវគោលការណ៍ជាមូលដ្ឋានស្តីពី "ប្រជាធិបតេយ្យសេរីពហុបក្ស" ដែលមានចែងក្នុងមាត្រា១ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងជំពូក៣ នៃនៃរដ្ឋធម្មនុញ្ញកម្ពុជាស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ជាពិសេស មាត្រា ៣១ ដែលចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស (....)" ក៏ដូចជាមាត្រា៨០ និង មាត្រា១០៤ នៃរដ្ឋធម្មនុញ្ញ ចែងថា៖ (១) តំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា (២) តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួនឃាត់ខ្លួន ឬឃុំខ្លួន ដោយសារមូលហេតុបានសំដែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញករណីយកិច្ចរបស់ខ្លួនឡើយ (៣) ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃរដ្ឋសភា នឹងអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា (៤) ក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនរដ្ឋសភា ហើយស្នើសុំការយល់ព្រមពីរដ្ឋសភា (៥) ការដកអភ័យឯកសិទ្ធិសភាត្រូវមានការយល់ព្រមដោយអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកសភាទាំងមូល ហើយ (៦) សភាអាចស្នើឲ្យផ្អាកការឃុំខ្លួន ឬការចោទប្រកាន់សមាជិកសភាណាមួយ ដោយអនុម័តតាមមតិភាគច្រើនបីភាគបួននៃសមាជិកសភាទាំងមូល។

១. *សំដែងការខកចិត្ត* ដោយសារគ្មានការរីកចម្រើនណាមួយច្បាស់លាស់ក្នុងការដោះស្រាយរឿងក្តីបច្ចុប្បន្នក្នុងរយៈពេលពីរឆ្នាំកន្លះកន្លងមកនេះ និងកម្រមានការឆ្លើយតបណាមួយជាលាយលក្ខអក្សរពីអាជ្ញាធរកម្ពុជាទៅនឹងការស្នើសុំព័ត៌មានរបស់សហភាពអន្តរសភា(IPU) *អាចសន្មត់ថា* កង្វះឆន្ទៈនយោបាយពីសំណាក់អាជ្ញាធរកម្ពុជា រាប់ទាំងសភាផងដែរ ក្នុងការដោះស្រាយករណីទាំងនេះ។

២. *សម្តែងកង្វល់យ៉ាងខ្លាំង* អំពីការរីកដាលខ្លាំងឡើងនៃស្ថានការណ៍ *មានការភ្ញាក់ផ្អើលជាពិសេស* អំពីការលើកឡើងថា គណៈបក្សសង្គ្រោះជាតិ(CNRP) អាចនឹងត្រូវបានរំសាយអនុលោមតាមវិសោធនកម្មដែលបានអនុម័តកាលពីពេលថ្មីៗនេះលើច្បាប់ស្តីពីគណបក្សនយោបាយ ដែលមិនស្របតាមបទដ្ឋានអន្តរជាតិស្តីពីសេរីភាពនៃការបង្កើតសមាគម ហើយបានមានគោលដៅយ៉ាងច្បាស់ទៅលើលោក សម រង្ស៊ី និងគណបក្សរបស់គាត់។

៣. *នៅតែមានកង្វល់យ៉ាងខ្លាំង*ថា សមាជិកសភាគណៈបក្សប្រឆាំងមួយផ្នែកធំ ដែលជាសមាសភាពថ្នាក់ដឹកនាំបច្ចុប្បន្ននៃគណៈបក្សប្រឆាំងតែមួយគត់នៅក្នុងរដ្ឋសភា បន្តប្រឈមការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិជាមូលដ្ឋានរបស់ពួកគេខាងសេរីភាពក្នុងការបញ្ចេញមតិយោបល់ ការបង្កើតសមាគម និងការជួប

ប្រជុំ *ដោយចាត់ទុកថា* ការរិតត្បិតទាំងនេះធ្វើឲ្យអន្តរាយដល់សិទ្ធិរបស់ពួកគេក្នុងការចូលរួមក្នុងជីវភាពនយោបាយ ព្រោះថាពួកគេបាននិងកំពុងត្រូវបានរារាំងដល់ការបំពេញតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ក្នុងនាមជាសមាជិកសភា និងជាសមាជិកគណបក្សប្រឆាំង ដោយសេរី ដោយគ្មានការភ័យខ្លាចពីការធ្វើទុក្ខបុកម្នេញ។

*៤.* *ស្នើយ៉ាងទទូចឲ្យ*គណៈបក្សកាន់អំណាច និងគណៈបក្សប្រឆាំងបន្តកិច្ចសន្ទនានយោបាយ និងដោះស្រាយជាបន្ទាន់ជាថ្មីម្តងទៀតចំពោះរឿងក្តីបច្ចុប្បន្ននេះ ដោយគោរពយ៉ាងមឹងម៉ាត់ទៅនឹងបទដ្ឋានសិទ្ធិមនុស្ស *ដោយចាត់ទុកថា* កិច្ចសន្ទនានេះអាចមានប្រយោជន៍ទៅបាន លុះត្រាណាតែមានលំហគ្រប់គ្រាន់សម្រាប់មតិមិនស្រប និងសម្រាប់ការអនុវត្តដោយសន្តិវិធីនូវសេរីភាពក្នុងការបញ្ចេញមតិ ការបង្កើតសមាគម និងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី

៥. *រំលឹកថា* អនុលោមតាមគោលការណ៍ និងគុណតម្លៃដែលត្រូវបានការពារដោយសហភាពអន្តរសភា (IPU) ដូចដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីលទ្ធិប្រជាធិបតេយ្យបានអនុម័តដោយសហភាពអន្តរសភា(IPU) នៅខែកញ្ញា ឆ្នាំ១៩៩៧ " ស្ថានភាពនៃលទ្ធិប្រជាធិបតេយ្យធានាថា ដំណើរការការងារប្រព្រឹត្តទៅ ដែលតាមរយៈនោះអំណាចត្រូវបានគេប្រគល់ឲ្យ ត្រូវបានប្រើប្រាស់ និងផ្លាស់ប្តូរ អនុញ្ញាតឲ្យមានការប្រកួតប្រជែងផ្នែកនយោបាយដោយសេរី និងជាដំណើរការនៃការចូលរួមដោយបើកចំហ សេរី និងគ្មានការរើសអើងដោយប្រជាពលរដ្ឋ ត្រូវបានអនុវត្តដោយអនុលោមតាមគោលការណ៍នីតិរដ្ឋ ទាំងជាលាយលក្ខអក្សរ និងទាំងខាងស្មារតី" និងសម្តែងនូវក្តីសង្ឃឹមសម្រាប់ការអត់ឱនឲ្យកាន់តែច្រើនឡើង និងការទទួលយកនៃតួនាទីរបស់គណបក្សប្រឆាំងនៅក្នុងប្រទេសកម្ពុជា *ដោយចាត់ទុកថា* វាជាការសំខាន់សម្រាប់គណបក្ស សង្គ្រោះជាតិ អាចឈ្មោះបោះឆ្នោតនៅថ្ងៃខាងមុខ *ដោយគូសបញ្ជាក់ជាថ្មី* អំពីលទ្ធភាពរបស់សហភាពអន្តរសភា(IPU) ដើម្បីជួយសម្រួលដល់កិច្ចសន្ទនានយោបាយ និងដើម្បីសម្រុះសម្រួលនៅក្នុងវិបត្តិនេះ និងដើម្បីផ្តល់ជំនួយបច្ចេកទេសដល់សភាកម្ពុជា ដើម្បីសម្រេចគោលដៅនេះ

៦. *ស្នើឲ្យ*អគ្គលេខាធិការពាំនាំនូវសេចក្តីសម្រេចនេះដល់អាជ្ញាធរមានសមត្ថកិច្ច អ្នកប្តឹង និងភាគីទីបីណាមួយដែលអាចមានតួនាទីក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធនានា។

៧. *ស្នើឲ្យ*គណៈកម្មាធិការបន្តពិនិត្យមើលករណីនេះ ហើយរាយការណ៍ត្រឡប់មកវិញតាមពេលវេលាដែលបានកំណត់។

**ចប់**